ភ្នំពេញ , ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៩៣

## ២. សេចក្តីជូនដំណឹងលេខ ០១៥ សជណ.សហវ

## ស្តីពីការចំណាយទៅបំពេញបេសកកម្ម និងទស្សនកិច្ចនៅបរទេស

ផ្អែកតាមព្រះរាជតំណាងឯកភាព របស់សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៣ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានកិត្តិយសទូលថ្វាយនិងជំរាបព្រះអង្គម្ចាស់ ឯកឧត្តម រដ្ឋមន្ត្រី គ្រប់ក្រសួង រដ្ឋលេខាធិការគ្រប់ស្ថាប័នអភិបាលគ្រប់ខេត្ត ក្រុងថា : ចាប់តាំងពី ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ តទៅ គណៈប្រតិភូកម្ពុជាដែលត្រូវបាន ទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាលអោយទៅបំពេញបេសកកម្ម និងទស្សនៈកិច្ចនៅបរទេស រយៈពេលខ្លីហើយត្រូវបានភាគី អញ្ជើញទទួលរ៉ាប់រងរាល់ការចំណាយផ្សេងៗ ហើយនោះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងកំណត់ផ្តល់ថវិកាបីយប័ណ្ណសំរាប់ដាក់ហោប៉ៅតាមប្រភេទដូចខាងក្រោម ÷

- ចាប់ពីថ្នាក់អនុរដ្ឋលេខាធិការឡើងលើ : ៤០ ដុល្លាអាមេរិក ក្នុងមួយថ្ងៃ ក្នុងមួយនាក់
- ចាប់ពីថ្នាក់ប្រធាននាយកដ្ឋានចុះក្រោម : ២០ ដុល្លាអាមេរិក ក្នុងមួយថ្ងៃ ក្នុងមួយនាក់ ការគិតគូរប្រាក់ហោប៉ៅនេះ ត្រូវបានកំណត់យ៉ាងខ្ពស់បំផុតត្រឹមរយៈពេល ១០ ថ្ងៃ ដោយមិនចាំបាច់ដោះស្រាយប្រាក់ត្រៀមបំរុងអ្វីផ្សេងទៀតទេ លើកលែងតែគណៈប្រតិភូណា ដែលមានគំរោងចំណាយដោយឡែកជាក់ស្តែង ។ ជំពូកចំណាយនេះនឹងត្រូវកត់ត្រាក្នុងផែនការចំណាយថវិកាបីយប័ណ្ណសំរាប់ឆ្នាំ ១៩៩៤ និងឆ្នាំបន្តទៀត ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា និង ត្រា

**សម រង្ស៊ី**